ទម្រង់ទី២៣

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តកំពង់ធំ**

លេខ៣៧០២/សជណ
/១៦

កំពង់ធំ ថ្ងៃទី...១៩... ខែកញ្ញា ឆ្នាំ២០១៦

# សេចក្តីជូនដំណឹង
# ស្តីពី
# ការរៀបចំបញ្ជីឈ្មោះអ្នកទទួលការ ឆ្នាំ២០១៧

រដ្ឋបាលខេត្តកំពង់ធំ នឹងរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៧ សម្រាប់ដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៧។ អ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការមានសិទ្ធិដាក់សំណើដេញថ្លៃគ្រប់គម្រោងមូលនិធិឃុំ សង្កាត់ទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

អ្នកទទួលការត្រូវបានបែងចែកជា០៣ប្រភេទ ៖

- ប្រភេទទី១៖ អ្នកទទួលការសំណង់ទូទៅ(ការងារសំណង់អគារ និងការងារបេតុង ...។ល។)
- ប្រភេទទី២៖ អ្នកទទួលការការងារដី (ប្រឡាយ ទំនប់ ផ្លូវដីស ផ្លូវក្រួសក្រហម ...។ល។)
- ប្រភេទទី៣៖ អ្នកទទួលការឯកទេស (អ្នកទទួលការដែលមានឧបករណ៍ និងជំនាញបច្ចេកទេសសម្រាប់ការងារ ពិសេស ឧទាហរណ៍ អណ្តូងស្នប់ ...។ល។)

អ្នកទទួលការត្រូវមានបុគ្គលិកបច្ចេកទេស និងសម្ភារៈបរិក្ខារគ្រប់គ្រាន់ ដូចមានបរិយាយនៅក្នុងពាក្យសុំចុះឈ្មោះក្នុងបញ្ជី ឈ្មោះអ្នកទទួលការ ដើម្បីអនុវត្តការងារទៅតាមប្រភេទដែលបានស្នើសុំ ហើយត្រូវមានបទពិសោធន៍អនុវត្តគម្រោងទាក់ទង នឹងប្រភេទនីមួយៗដែលបានស្នើសុំយ៉ាងតិច០២ ក្នុងអំឡុងពេល៥ឆ្នាំចុងក្រោយ។ អនុគណៈកម្មការបុរេលក្ខណសម្បត្តិនឹងចុះពិនិត្យ ដល់ទីតាំងក្រុមហ៊ុនរបស់អ្នកទទួលការ និងវាយតម្លៃសមត្ថភាពបច្ចេកទេសដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដូចមានបរិយាយនៅក្នុង ពាក្យសុំចុះបញ្ជី ព្រមទាំងពិនិត្យមើលគុណភាពការងារ ភាពស្មោះត្រង់ ការអនុវត្តការងារទាន់ពេលវេលា និងកិច្ចសហប្រតិបត្តិការ របស់អ្នកទទួលការជាមួយម្ចាស់គម្រោង ដោយផ្អែកលើកំណត់ត្រាកន្លងមក។ លទ្ធផលនៃការវាយតម្លៃនេះ អនុគណៈកម្មការ បុរេលក្ខណសម្បត្តិ នឹងដាក់ជូនអភិបាលរាជធានី ខេត្ត ដើម្បីពិនិត្យនិងសម្រេច។ អ្នកទទួលការទាំងឡាយណា ដែលត្រូវបានរកឃើញថាមានការពាក់ព័ន្ធនឹងការឃុបឃិតសុំគ្រលំគ្នា ការក្លែងបន្លំ និងអំពើពុករលួយ ហើយចាប់ពីពេលដែលត្រូវបានដកសិទ្ធិជាផ្លូវការ អ្នកទទួលការនោះ នឹងមិនត្រូវបានពិចារណាក្នុងការបញ្ចូលឈ្មោះទៅក្នុងបញ្ជីឈ្មោះអ្នកទទួលការឡើយ។

អាស្រ័យហេតុនេះ បើអ្នកទទួលការមានបំណងចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ សូមប្រញាប់រួសរាន់មកដាក់ពាក្យសុំចុះ ឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការនៅ ទីចាត់ការផែនការនិងវិនិយោគនៃសាលាខេត្តកំពង់ធំ ចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ **ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ វេលាម៉ោង៥:០០ ល្ងាច**។ ចំពោះអ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឆ្នាំកន្លងមក ក៏ត្រូវដាក់ពាក្យ សុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការជាថ្មីឡើងវិញដែរ។ អ្នកទទួលការអាចមកយកពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការនៅទីចាត់ការផែនការ និងវិនិយោគដោយឥតបង់ថ្លៃតាមអាសយដ្ឋាន ស្ថិតនៅក្នុងសាលាខេត្តកំពង់ធំ ឬអាចទាញយកពីក្នុងគេហទំព័ររបស់ គ.ជ.អ.ប។

**អភិបាល**

**អ៊ុត សំអន**